វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*

យើងទាំងអស់គ្នារួមរស់នៅក្នុងសង្គមនិងភពផែនដីមួយដែលមានសន្តិភាព បរិយាបន្ន វិបុលភាព និងនិរន្តរភាព
*We all live in a peaceful, inclusive, prosperous, and sustainable society and planet.*

**លេខ**.: ៩០៧../BWG/2026

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** គោរពផ្ញើជូន ធាតុចូលសំខាន់ៗរបស់ក្រុមការងារថវិកា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ចំពោះរបាយការណ៍វឌ្ឍនភាព ស្តីពីការអនុវត្តដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និងសូមស្នើឲ្យមានឱកាសដើម្បីលើកឡើងក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី២ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦។
**យោង៖** លិខិតអញ្ជើញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៨៦៤១ សហវ-ល.ស.អ.គ.ហ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ តាងនាមក្រុមការងារថវិកា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអបអរសាទរដល់រាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលប្រាំមួយខែដើមឆ្នាំ២០២៦។

យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាជ្រាបថា សមាជិកក្រុមការងារថវិកា បានពិនិត្យមើលរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី២ ឆ្នាំ ២០២៦ ស្តីពីការអនុវត្តដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ព្រមទាំងឯកសារពាក់ព័ន្ធទាំងឡាយដោយយកចិត្តទុកដាក់បំផុត។ ជាលទ្ធផល ក្រុមការងារ បានចងក្រងជាធាតុចូលសំខាន់ៗទៅលើរបាយការណ៍ ដូចដែលបានភ្ជាប់ជូនមកជាមួយនេះ ជូនដល់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជាធាតុចូល ក្នុងការជជែកពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធនាពេលខាងមុខនេះ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ យើងខ្ញុំសូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាទទួលយកនូវធាតុចូលសំខាន់ៗ និងសំនូមពរដោយក្តីអនុគ្រោះ និងសូមស្នើឲ្យមានឱកាសដើម្បីលើកឡើងក្នុងកិច្ចប្រជុំជជែកពិភាក្សាលើឯកសារនេះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ៣កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២៦

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ កញ្ញា ឆាយ តុលា លេខាធិការ ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ តាមរយៈទូរសព្ទ/តេលេក្រាម 012 270 244

ជ.ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល

**នាយកប្រតិបត្តិអង្គការវេទិកានៃ**
**អង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា**

NGO FORUM ON CAMBODIA

**សឿង សារឿន**